ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ: ៦២៤ "ក្រ.វ"

-ចុះថ្ងៃទី១៤ ខែ **សីហា** ឆ្នាំ**២០១៩**

-សំណុំរឿងព្រហ្មទណ្ឌលេខ**៣២២៤**

ចុះថ្ងៃទី**២៩** ខែ**ឧសភា** ឆ្នាំ**២០១៨**

-ស៊ើបសួរលេខ **១៩៤០**

ចុះថ្ងៃទី**០៨** ខែ**មិថុនា** ឆ្នាំ**២០១៨**

-ជំនុំជម្រះលេខ **១៣៤៣**

ចុះថ្ងៃទី **២៦** ខែ **មេសា** ឆ្នាំ**២០១៩**

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ៣០ ខែ **កក្កដា** ឆ្នាំ**២០១៩** វេលាម៉ោង ៨ និង ៣០នាទីព្រឹក នៅសាលសវនាការទី**៥** ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកស្រីអនុប្រធាន [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ **៣២២៤** ចុះថ្ងៃទី**២៩** ខែ**ឧសភា** ឆ្នាំ**២០១៨** ដែលមានជន**ជាប់ចោទឈ្មោះ [redacted] បវិញ្ញា** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ **០១០៧០៨** ៣៣៣មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៥០៣A ក្រុម៨ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

អង្គហេតុនៃរឿងមានដូចតទៅ

-កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ មានកេសបញ្ជើដែលមានលេខកូដ CY502098108DE ផ្ញើពីប្រទេសអាល្លឺម៉ង់ចូលមកប្រទេសកម្ពុជា តាមរយៈ Apele Wagner មានអ្នកទទួលឈ្មោះ [redacted] **បវិញ្ញា** ភេទប្រុសដោយមានការសង្ស័យបង្កប់ថ្នាំញៀន នៅវេលាម៉ោង ១៤ និង ០៥នាទី ថ្ងៃខែឆ្នាំដដែល ក្រុមស៊ើបអង្កេតបទល្មើសឆ្លងដែនព្រំដែន TCT បានចុះធ្វើការត្រួតពិនិត្យកញ្ចប់នោះ ជាលទ្ធផលរកឃើញថ្នាំញៀនប្រភេទ **អ៊ិច ស្តាស៊ី (គ្រាប់ថ្នាំក្រវីពណ៌ទឹកក្រូច)** ច្រកចូលក្នុងកញ្ចប់ផ្លាស្ទិច ពណ៌សថ្លាចំនួន ០៥កញ្ចប់ ដែលមានទម្ងន់សុទ្ធសរុប ៨.២៣៥ក្រាម។

-**បានឃើញ** របាយការណ៍លេខ ០៥៧ របផស/១៨ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៨ របស់នាយកដ្ឋានចារកម្ម ក្រុមស៊ើបអង្កេតបទល្មើសឆ្លងដែន។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៨៥៦ អ.យ.ព ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ**ដីកាសន្និដ្ឋានស្នាពរលេខ ១១០៥ អ.យ.ត ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៩ របស់តំណាង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសម្រេចលើកលែងចោទប្រកាន់លេខ១៥៨៩"រ" ដ.ដ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៥៩០ "រ" ដ.ដ ចុះថ្ងៃទី០៣ ខែមេសាឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ដោយសេចក្តីគោរព

-ក្រឡាបញ្ជីអានសាវតាជាតិរបស់ជនជាប់ចោទ។

-ក្រឡាបញ្ជីអានអង្គហេតុបញ្ជូនមកជំនុំជម្រះ។

-ក្រឡាបញ្ជីអានកំណត់ហេតុត្រួតពិនិត្យឆែកឆេរកញ្ចប់បញ្ជើ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨។

-ក្រឡាបញ្ជីអានកំណត់ហេតុកេសវត្ថុតាង ដកយកសំណាកសង្ស័យជាសារធាតុញៀនបញ្ជូនទៅក្រុម ការងារចំពោះកិច្ច ដើម្បីត្រួតពិនិត្យធ្វើការវិភាគលើសារធាតុចាប់យកក្នុងបទល្មើសគ្រឿងញៀន។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **១៥២៦២/១៨ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់អំណានសាវតាជាតិរបស់ជនជាប់ ចោទ,ក្រោយពីបានស្តាប់អង្គហេតុបញ្ជូនមកជំនុំជម្រះ,ក្រឡាបញ្ជីអានកំណត់ហេតុត្រួតពិនិត្យឆែកឆេរកញ្ចប់ញើ និង ឃើញថាជនជាប់ចោទឈ្មោះ [redacted] **បរិញ្ញា** ពិតជាបានប្រព្រឹត្តិអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ពិតមែន ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្នាពរលេខ **១១០៥ អ.យ.ត** ចុះថ្ងៃទី២៧ខែមីនាឆ្នាំ២០១៩ទុកជាបានការដដែល និងសុំឲ្យឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេច ផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **បរិញ្ញា** ធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្លួនជាមេធាវីការពារ សិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **បរិញ្ញា** ក្រោយពីបានពិនិត្យលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣២២៤ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទឈ្មោះ [redacted] **បរិញ្ញា** សូមធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិដូច កូនក្តីខ្លួនឈ្មោះរ័ត្ន បរិញ្ញា ដែលបច្ចុប្បន្នកំពុងនៅក្រៅឃុំពាក់ព័ន្ធករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន កាលពីថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ ២០១៨ ដែលកន្លងមកនេះតុលាការបានចោទប្រកាន់កូនក្តីរបស់ខ្លួនពីបទជួញដូរ គ្រឿងញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចនេះខ្លួនសូមអនុញ្ញាត្តិលើកឡើងនៅ ករណីមួយចំនួនជូនក្រុមប្រឹក្សាជំនុំជម្រះដើម្បីធ្វើការពិចារណា ដោយសារតែចំពោះការធ្វើឥរិ៍ន់នេះគេដាក់លេខ ទូរស័ព្ទរបស់គាត់ ហើយពេលនោះគាត់ជាអ្នកទៅទទួលយកឈ្មោះការខលពីប្រៃសណីយ៍កម្ពុជាហើយគាត់មិន បានដឹងថាតើកញ្ចប់ដែលគេផ្ញើមកពីក្រៅប្រទេសនោះជាកញ្ចប់អ្វីទេ ទីពីរប្រសិនបើកគេផ្ញើគ្រឿងញៀនពិតមែន គាត់ពិតជាមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការទៅទទួលឥរិ៍ន់ គាត់មិនអាចមានការធ្វេសប្រហែលក្នុងការទទួល

ឥវ៉ាន់នោះទេគាត់ត្រូវប្រុងប្រយ័ត្នខ្ពស់ បើគាត់បានដឹងថានៅក្នុងកញ្ចប់បញ្ជើនោះជាគ្រឿងញៀន ទីបីឈ្មោះ [redacted] បរិញ្ញា អាចជាជនរងគ្រោះក្នុងការទទួលឥវ៉ាន់នោះ ដោយសារតែតុលាការបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ជនបរទេសឈ្មោះ Apele Wagner ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] បរិញ្ញា ដោយផ្អែកលើស្ថានភាពដែលខ្លួនបានលើកឡើងក្នុងសេចក្តីសន្និដ្ឋានការពារនិងប្តឹងសុំឲ្យលោកស្រីប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចលើកលែងចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] **បរិញ្ញា** បាននិយាយសំដីចុងក្រោយបង្អស់ថា៖ **គ្មាន "មូលហេតុអវត្តមាន"**

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិជនជាប់ចោទឈ្មោះ [redacted] **បរិញ្ញា**

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានអង្គហេតុដែលបញ្ជូនមកជំនុំជម្រះ

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុត្រួតពិនិត្យឆែកឆេរកញ្ចប់បញ្ជើ

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុកេសវត្ថុតាង

ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀន

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ**៣២២៤**ចុះថ្ងៃទី**២៩** ខែ **ឧសភា** ឆ្នាំ**២០១៨** តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **១៥៩០** "រ" ដ.ដ ចុះថ្ងៃទី **០៣** ខែ **មេសា** ឆ្នាំ **២០១៩** របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **បរិញ្ញា** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-កាលពីថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨ ក្រុមស៊ើបអង្កេតបទល្មើសឆ្លងកាត់ព្រំដែនTCT បានចុះត្រួតពិនិត្យកេសបញ្ជើដែលមានលេខកូដ CY502098108DE ពីប្រទេសអាល្លឺម៉ង់ចូលមកប្រទេសកម្ពុជាតាមរយៈApele Wagner មានអ្នកទទួលឈ្មោះ [redacted] **បរិញ្ញា**។ ក្រោយពេលត្រួតពិនិត្យរកឃើញគ្រឿងញៀនប្រភេទ **អ៊ិច ស្តាស៊ី (គ្រាប់ថ្នាំក្រវីពណ៌ទឹកក្រូច)** ច្រកចូលក្នុងកញ្ចប់ផ្លាស្ទិច ពណ៌សផ្តាំចំនួន ០៥កញ្ចប់ ដែលមានទម្ងន់សុទ្ធសរុប ៨.២៣៥ក្រាម។

៣-តាមការបាយការណ៍លេខ ០៥៧ **របជស/១៨** ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៨ របស់នាយកដ្ឋានចារកម្មក្រុមស៊ើបអង្កេតបទល្មើសឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ បានធ្វើការសន្និដ្ឋានថា៖ជនសង្ស័យឈ្មោះ [redacted] **បរិញ្ញា**ពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន

កាលពីថ្ងៃទី២៥ខែឧសភាឆ្នាំ២០១៨ វេលាម៉ោង១៣ និង ៣០នាទី នៅចំណុចរាជធានីភ្នំពេញ ប្រាកដមែន។

៤-តាមកំណត់ហេតុត្រួតពិនិត្យឆែកឆេរកញ្ចប់បញ្ជើដែលមានលេខកូដ CY502098108DE ផ្ញើពីប្រទេសអាល្លឺម៉ង់ចូលមកប្រទេសកម្ពុជាតាមរយៈ Apele Wagner ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ ឃើញមាន ប្រភេទគ្រាប់ថ្នាំពណ៌ផ្កាឈូកទម្ងន់ ៨៣១៥ក្រាម (ប្រាំបីពាន់បីរយដប់ប្រាំក្រាម)។ ក្រោយពេលធ្វើតេស្តបឋមលទ្ធផលបង្ហាញថា សារធាតុញៀនខុសច្បាប់ (ប្រភេទ Ecstasy) ថ្នាំគ្រឿ។

៥-តាមកំណត់ហេតុត្រួតពិនិត្យឆែកឆេរកញ្ចប់បញ្ជើ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿងក្តីមានលក្ខណៈស៊ីសង្វាក់បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **បវិញ្ញា** ពិតជាប្រព្រឹត្តអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ ពិតប្រាកដមែន។

៦-សារធាតុញៀនដែលចាប់ជនជាប់ចោទប្រភេទកញ្ចប់ថ្នាំគ្រាប់ ពណ៌ផ្កាឈូក(ប្រភេទ Ecstasy) ថ្នាំគ្រឿទម្ងន់ ៨៣១៥ក្រាម (ប្រាំបីពាន់បីរយដប់ប្រាំក្រាម) ដែលមានសារធាតុញៀនឈ្មោះ **អឹម ដេ អឹម អា (MDMA)** មានកម្រិតភាពសុទ្ធចំនួន **៥៣.៦១%** (ហាសិបបីកណ្តាក់សញ្ញាហុកសិបមួយភាគរយ) ដូចនេះ បរិមាណសុទ្ធ **អឹម ដេ អឹម អា(MDMA)** មានបរិមាណសុទ្ធចំនួន $\frac{៨២៣៥X៥៣.៦១}{១០០}$ =**៤៤១៤.៧៨**ក្រាម ឃើញថា សារធាតុញៀនឈ្មោះ **អឹម ដេ អឹម អា(MDMA)** មានបរិមាណសុទ្ធសរុបចំនួន **៤៤១៤.៧៨**ក្រាម ដូចនេះ បរិមាណសុទ្ធចាប់ពី **២៤០**ក្រាម កំរិតនៃការផ្តន្ទាទោសបរិមាណសារធាតុញៀនគឺតាមមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **២០ (ម្ភៃ) ទៅ ៣០ (សាមសិប) ឬអស់មួយជីវិត** និងពិន័យជាប្រាក់ពី **៤០.០០០.០០០ (សែសិបលាន) រៀល** ទៅ ១០០.០០០.០០០ **(មួយរយលាន) រៀល**។

៧-សកម្មភាពរបស់ជនជាប់ចោទដែលបានទទួលយកថ្នាំញៀន ក្នុងគោលបំណងយកទៅលក់ឲ្យអ្នកដ៏ទៃ ដើម្បីទទួលបានប្រាក់ចំណេញត្រូវបានច្បាប់កំណត់ថា ជាបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ហើយបញ្ជូតិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី **២០(ម្ភៃ)ទៅ ៣០ (សាមសិប) ឬអស់មួយជីវិត** និងផ្តន្ទាទោសពិន័យជាប្រាក់ពី **៤០.០០០. ០០០ (សែសិបលាន) រៀល** ទៅ ១០០.០០០.០០០ **(មួយរយលាន) រៀល** តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨- **អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដ៏ទៃ** ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈរបៀបរៀបរយសង្គមដែលច្បាប់ហាមឃាត់ ជាពិសេសបំពានទៅនឹងមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-ជនជាប់ចោទឈ្មោះ [redacted] **បវិញ្ញា** ជានីតិជន និងជាជនដែលមាននីតិសម្បទាស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

១០-ការលើកឡើងរបស់តំណាងអយ្យការ ក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការដោយបានលើកឡើងពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **បវិញ្ញា** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ហើយស្នើសុំតម្កល់ការចោទប្រកាន់នោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

១១.មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានស្នើសុំឱ្យឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចលើកលែងចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] **បវិញ្ញា** ការស្នើសុំនេះពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់នោះ

ទេ គប្បីតុលាការពុំលើកយកមកពិចារណានោះទេ។

១២-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **បវិញ្ញា** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣-វត្ថុតាងចាប់យកមានហិបដែកពណ៌ដោះគោបិទជិតចំនួនមួយដោយមានហត្ថលេខារបស់គណៈកម្មការចម្រុះដែលសម្រេចបើកកញ្ចប់បញ្ជីដែលមានលេខកូដCY502098108DE ដោយសរសេរថា កញ្ចប់ថ្នាំគ្រាប់ ពណ៌ផ្កាឈូក ជាសារធាតុញៀនខុសច្បាប់ (ប្រភេទEcstasy) ថ្នាំគ្រឿទម្ងន់ **៨២៣៥** ក្រាម (ប្រាំបីពាន់ពីររយសាមសិបប្រាំក្រាម)និងសំបកកេសដែលមានកូដCY502098108DE ចំនួនមួយត្រូវបានចៅក្រមស៊ើបសួរសម្រេចរឹបអូសបំផ្លាញចោលតាមដីកាសម្រេចលេខ ៥១៨ ព្រ.ទ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ រួចហើយគប្បីតុលាការពុំលើកយកមកពិចារណានោះទេ។

ហេតុផ្លូវច្បេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] **បវិញ្ញា** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៧០៨៣៣៣ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៥០៣A ក្រុម៨សង្កាត់កាកាបខណ្ឌដង្កោ រាជធានីភ្នំពេញ។

ដាក់ពន្ធនាគារកំណត់ ៣០ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨0.000.000 **(ប៉ែតសិបលាន)រៀល**។

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-បង្គាប់ឱ្យចាប់ខ្លួននិងឃុំខ្លួនឈ្មោះ [redacted] **បវិញ្ញា** តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០១៩ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **បវិញ្ញា** ។

ទុកសិទ្ធិប្តឹងសិទ្ធប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

ក្រឡាបញ្ជីសវនាការ	**ចៅក្រមប្រឹក្សា**	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
(ហត្ថលេខា និងត្រា)	(ហត្ថលេខា និងត្រា)	(ហត្ថលេខា និងត្រា)	(ហត្ថលេខា និងត្រា)
[redacted]			

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០១៩

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner